# ការព្យាបាល៖ ជំងឺរលាកថ្លើមប្រភេទ C

មានថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺរលាកថ្លើមប្រភេទ C ។ ប្រភេទថ្នាំទាំងនេះត្រូវបានគេហៅថា ថ្នាំទប់ទល់ប្រឆាំងនឹងវីរុសដោយផ្ទាល់ (Direct Acting Antivirals - DAAs)។

ការព្យាបាលពាក់ព័ន្ធនឹងការលេបថ្នាំគ្រាប់រយៈពេល 8 ឬ 12 សប្តាហ៍។ មិនមានការចាក់ថ្នាំទេ។

មនុស្សភាគច្រើនមានអារម្មណ៍ល្អនៅពេលប្រើថ្នាំនេះ។

មនុស្សមួយចំនួនជួបប្រទះផលប៉ះពាល់ខ្លះ ប៉ុន្តែជាធម្មតាវាស្រាល។
ផលប៉ះពាល់ទាំងនេះ អាចរួមមាន៖
- ឈឺក្បាល
- អស់កម្លាំង
- មានអារម្មណ៍ឈឺ និងមិនឃ្លាន

ប្រសិនបើអ្នកជាមនុស្សពេញវ័យដែលមានប័ណ្ណ Medicare អ្នកអាចទទួលបានការព្យាបាល។ ការព្យាបាលមានផ្តល់ជូនដែលមានសុវត្ថិភាព និងនៅតែដំណើរការ ប្រសិនបើ៖

·បច្ចុប្បន្នអ្នកកំពុងចាក់ថ្នាំគ្រឿងញៀន
·អ្នកផឹកស្រា
·អ្នកមានរោគវិនិច្ឆ័យសុខភាពផ្លូវចិត្ត
·អ្នកលេបថ្នាំព្យាបាលផ្សេងទៀត។
·អ្នកមានការខូចថ្លើម

អ្នកអាចទិញថ្នាំនេះបានលើគម្រោងការជំនួយផ្នែកឱសថ (Pharmaceutical Benefits Scheme - PBS) ដែលមានតម្លៃដូចគ្នានឹងថ្នាំព្យាបាលធម្មតាដែរ។

ការព្យាបាលអាចមានផ្តល់តាមតម្រូវការ។ ដោយសារអាចមានលទ្ធភាពឆ្លងជំងឺរលាកថ្លើមប្រភេទ C ម្តងទៀត ការធ្វើតេស្តជាប្រចាំមានសារៈសំខាន់ ប្រសិនបើអ្នកមានហានិភ័យ។

LiverWELL
Incorporating HEPATITIS VICTORIA

GILEAD
Supported by a grant from Gilead Sciences